ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រម**

លេខ ២៣៣ "ច" ក្រ២

ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០២៣

សំណុំរឿងព្រហ្មទណ្ឌលេខ ៣៥៤០

ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០២២

ស៊ើបសួរលេខ ២៦៩៤

ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០២២

ជំនុំជម្រះលេខ ៤៩៣៤

ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២២

**តាមនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០២៣

វេលាម៉ោង ៨ និង ០០ នាទីព្រឹក ដោយមានសមាសភាព:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមក្រុមប្រឹក្សា

លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមក្រុមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៥៤០ ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០២២ ដែលមានជនជាប់ចោទឈ្មោះ [redacted] **សុខហេង** ហៅ **សុខ** ភេទប្រុស អាយុ ២៧ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ៖ អ្នកដឹកថ្នាំពេទ្យឱ្យក្រុមហ៊ុន ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ឆ្នាំង ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅបន្ទប់ជួល សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] គុល "រ" ម្តាយឈ្មោះ [redacted] ហួរ "រ" ជានីតិជន ទោសពីមុនគ្មាន ។

ឃាត់ខ្លួនថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០២២ , ឃុំខ្លួនថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០២២ (ម១)

ពីបទ គំរាមកំហែងហែកកេរ្តិ៍មានស្ថានទម្ងន់ទោសដោយសារការអនុវត្តជាក់ស្តែងនូវការគំរាមកំហែង ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២២ និងថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៧២ និងមាត្រា ៣៧៤ នៃក្រមព្រហ្មទណ្ឌ ។

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុគីម** ភេទស្រី កើតថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០២ សញ្ជាតិខ្មែរ មុខរបរ លក់ដូរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ៦៤៦ ភូមិកញ្ចាំ ឃុំកញ្ចាំ ស្រុកពារាំង ខេត្តព្រៃវែង ។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីអំឡុងខែ មីនា ឆ្នាំ ២០១៨ ជនជាប់ចោទឈ្មោះ [redacted] សុខហេង ហៅ សុខ ភេទប្រុស អាយុ ២៧ ឆ្នាំ មានទីលំនៅបច្ចុប្បន្នស្នាក់នៅបន្ទប់ជួល សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ និងជនរងគ្រោះឈ្មោះ



Scanned with CamScanner

[redacted] សុភីម ភេទស្រី អាយុ ២០ ឆ្នាំ ផ្ដើមមានទំនាក់ទំនងស្នេហាជាមួយគ្នា ឈានដល់ការលួងលោមឱ្យជនរងគ្រោះឈ្មោះ [redacted] សុភីម អាយុ ២០ ឆ្នាំ ផ្ញើរូបថតអាក្រាតកាយ និងឃ្លីបវីដេអូអាក្រាតកាយរបស់ជនរងគ្រោះផ្ញើឱ្យជនជាប់ចោទតែម្ដង ។ រហូតមកដល់អំឡុងខែមេសា ឆ្នាំ ២០២០ ជនជាប់ចោទឈ្មោះ [redacted] សុខហេង ហៅ សុខ និងជនរងគ្រោះឈ្មោះ [redacted] សុភីម បានចាប់ផ្ដើមមានទំនាស់គ្នា ដោយហេតុថា ជនជាប់ចោទឈ្មោះ [redacted] សុខហេង តែងតែបបួលជនរងគ្រោះទៅផ្ទះសំណាក់ និងទាមទារឱ្យផ្ញើរូបថតអាក្រាតកាយជារឿយៗ ទើបជនរងគ្រោះបានផ្ដាច់ទំនាក់ទំនងស្នេហាជាមួយជនជាប់ចោទឈ្មោះ [redacted] សុខហេង តែម្ដង ។ ក្រោយពីជនរងគ្រោះផ្ដាច់ទំនាក់ទំនងស្នេហាមកជនជាប់ចោទឈ្មោះ [redacted] សុខហេង បានផ្ញើសារគំរាមជនរងគ្រោះតាមប្រព័ន្ធ SMS ឱ្យមកដេកផ្ទះសំណាក់ជាមួយជនជាប់ចោទ បើមិនធ្វើតាមទេ នោះនឹងបង្ហោះរូបភាពអាក្រាតកាយ និងឃ្លីបវីដេអូអាក្រាតកាយរបស់ជនរងគ្រោះជាសាធារណៈ ។ ក្រោយមកនៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២២ ជនជាប់ចោទឈ្មោះ [redacted] សុខហេង ក៏បង្ហោះរូបភាពអាក្រាតកាយរបស់ជនរងគ្រោះឈ្មោះ [redacted] សុភីម តាមគណនីហ្វេសបុកឈ្មោះ “Proeung Sophim“ និងនៅថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០២២ បានបង្ហោះរូបភាពអាក្រាតកាយ ព្រមទាំងវីដេអូអាក្រាតកាយរបស់ជនរងគ្រោះ តាមរយៈគណនីហ្វេសបុកឈ្មោះ “Oun Pov” ដោយភ្ជាប់ខ្លឹមសារសសេរថា “នឹកអូនណាស់មើលលេងសិនទៅសម្រាប់អ្នកច្បាស់តិចទៀតឃើញរឿងហើយលក់ឱ្យគេ” ។ រហូតដល់ថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០២២ ឈ្មោះ [redacted] សុភីម ភេទស្រី អាយុ ២០ ឆ្នាំ បានមកដាក់ពាក្យបណ្ដឹងនៅនាយកដ្ឋានពត៌មានវិទ្យា នៃក្រសួងមហាផ្ទៃ ឈានដល់ការឃាត់ខ្លួនជនត្រូវចោទឈ្មោះ [redacted] សុខហេង ហៅ សុខ នៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០២២ នាំយកមកសាកសួរតែម្ដង ។

បានឃើញរបាយការណ៍សំយោគលេខ ០០៣/២២ របក.កង.ពទ ចុះថ្ងៃទី២១ ខែ កក្កដា ឆ្នាំ ២០២២ របស់ការិយាល័យសហប្រតិបត្តិការទប់ស្កាត់បទល្មើសពត៌មានវិទ្យា ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ ២៦៩៨ អ.យ.ធ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៤៦៦១ អ.យ.ធ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៦២៤២ “អ” ជ.ជ ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ [redacted] **សុខហេង ហៅ សុខ** បានឆ្លើយថា៖ នៅដើមឆ្នាំ ២០១៨ ខ្លួនជាកម្មករសំណាក់ស្រុកមកពីខេត្តកំពង់ឆ្នាំង ស្នាក់នៅផ្ទះជួលម្ដុំផ្សារសាំហាន់ស្ថិតនៅក្នុងសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រកបមុខរបរជាអ្នកដឹកថ្នាំពេទ្យ ហើយខ្លួនបានស្គាល់ឈ្មោះ [redacted] សុភីម ជាអ្នករស់នៅបន្ទប់ជួលជាប់ខ្លួន បានសន្យាជាមួយគ្នាថានឹងយកគ្នាជាគូរអនាគត ដោយខ្លួនតែងតែរួមភេទជាមួយគ្នា នៅក្នុងបន្ទប់ជួលរបស់ឈ្មោះ [redacted] សុភីម នៅពេលដែលពូមីងរបស់គាត់មិននៅផ្ទះ ។ ស្នេហានេះអូសបន្លាយរយៈពេលជិត ០២ឆ្នាំ ក្នុងពេលដែលពួកខ្លួនទាំងពីរនៅឆ្ងាយពីគ្នាក្នុងអំឡុងពេល នៃការផ្ទុះរាលដាលជម្ងឺកូវីដ-១៩ ដើមឆ្នាំ ២០២០ ដោយខ្លួនទៅរស់នៅស្រុកកំណើតវិញ ហើយឈ្មោះ [redacted] សុភីម ក៏ត្រឡប់ទៅស្រុកកំណើតដែរ



Scanned with CamScanner

ពេលទៅឆ្ងាយពីគ្នាខ្លួនតែងតែ Call Video ជាមួយឈ្មោះ [redacted] សុភីម តាមបណ្ដាញទំនាក់ទំនង Messenger ដោយពួកខ្លួនទាំងពីរនាក់ តែងតែផ្ញើរូបភាព និងវីដេអូអាក្រាតកាយ ស្រើបស្រាលផ្លូវភេទ និងលេងប្រដាប់ភេទឱ្យគ្នាមើលទៅវិញទៅមក ដើម្បីសម្រេចចំណង់ផ្លូវភេទរៀងៗខ្លួន ។ ស្រាប់តែក្រោយទំនាក់ទំនងពួកខ្លួនទាំងពីរនាក់ឃ្លាតឆ្ងាយពីគនាបន្តិចម្ដងៗ ដោយឈ្មោះ [redacted] សុភីម ណាយចិត្តពីខ្លួនបន្តិចម្ដងៗ បម្រុងនឹងមានអ្នកថ្មី ។ ក្រោយមកនៅពាក់កណ្ដាលឆ្នាំ ២០២១ ខ្លួនក៏ផ្លាស់ប្ដូរមករស់នៅម្ដុំឈូកវ៉ា២ជាមួយនឹងក្រុមគ្រួសារ ពេលនោះដែលខ្លួនខឹងឈ្មោះ [redacted] សុភីម មានទំនាក់ទំនងស្នេហាជាមួយអ្នកថ្មី នៅដើមឆ្នាំ ២០២២ ខ្លួនចាប់ផ្ដើមប្រើគណនីហ្វេសបុកឈ្មោះ [redacted] Pov មិនចាំថ្ងៃខែឆ្នាំបង្កើត និងគណនីហ្វេសបុកឈ្មោះ [redacted] Sophim" បង្កើតនៅក្នុងខែឧសភា ឆ្នាំ ២០២០ ក្នុងពេលដែលរសើនៅម្ដុំផ្សារសាំហាន់យករូបថត និងវីដេអូដែលពួកខ្លួនផ្ញើឱ្យគ្នានាពេលកន្លងមកបង្ហោះជាសាធារណៈ ក្នុងគណនីហ្វេសបុកទាំងពីរ ខាងលើ ដើម្បីឱ្យឈ្មោះ [redacted] សុភីម ខ្មាសគេ ខូចកេត្តិយស និងកុំឱ្យបុរសផ្សេងមកស្រឡាញ់ឈ្មោះ [redacted] សុភីម បាន ។

ក្រឡាបញ្ជីអានចម្លើយជនរងគ្រោះឈ្មោះ [redacted] **សុភីម** បានឆ្លើយថា៖ កាលពីអំឡុងឆ្នាំ ២០១៨ ខ្លួនបានមករស់នៅរាជធានីភ្នំពេញ ដើម្បីរៀនបន្ត ហើយបានស្គាល់ជាមួយឈ្មោះ [redacted] សុខហេង ព្រោះគាត់ជាអ្នកជិតខាង ។ លុះដល់អំឡុងខែមីនា ឆ្នាំ ២០១៨ ខ្លួនមានទំនាក់ទំនងស្នេហាជាមួយគ្នា ប្រហែលមួយឆ្នាំកន្លងមកឈ្មោះ [redacted] សុខហេង បានសុំឱ្យខ្លួនថតរូបអាក្រាតកាយជារូបភាព និងមានឃ្លីបវីដេអូ ជាច្រើនលើកច្រើនសារផ្ញើទៅឱ្យគាត់តាមរយៈ Telegram និង Messenger ។ នៅខែមេសា ឆ្នាំ ២០២០ ដោយមើលឃើញឈ្មោះ [redacted] សុខហេង មិនមានការងារច្បាស់លាស់ និងមានទង្វើខុសឆ្គងមានគំនិតមិនល្អដែលឧស្សាបបួលខ្លួនទៅផ្ទះសំណាក ព្រមទាំងទាមទារឱ្យខ្លួនថតរូបអាក្រាតទៅគាត់រហូត ដោយខ្លួនគិតថាពុំអាចផ្ញើវាសនាលើឈ្មោះ គុល សុខហេង បានទៀត ខ្លួនក៏បានផ្ដាច់ទំនាក់ទំនងស្នេហាជាមួយគាត់ ។ ឈ្មោះ [redacted] សុខហេង ព្រមបែកគ្នាពីខ្លួនមិនមានរករឿងអ្វីនោះទេ ។ លុះដល់អំឡុងខែឧសភា ឆ្នាំ ២០២១ ឈ្មោះ [redacted] សុខហេង តែងតែគំរាមខ្លួនតាមរយៈ SMS , Telegram និង Messenger ឱ្យខ្លួនទៅដេកជាមួយគាត់នៅផ្ទះជួល បើខ្លួនមិនធ្វើតាមការគំរាមគំហែងគាត់នឹង Post រូបអាក្រាតកាយរបស់ខ្លួនតាមហ្វេសបុកតែខ្លួនបាននិយាយប្រាប់គាត់ថា ចាំខ្លួនទៅជួបតែខ្លួនមិនបានទៅតាមអ្វីដែលគាត់ទាមទារនោះទេ ។ លុះដល់ថ្ងៃទី ០៧ ខែមករា ឆ្នាំ ២០២២ ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយប្ដីរបស់ខ្លួន ស្រាប់តែនៅថ្ងៃទី ១១ ខែមករា ឆ្នាំ ២០២២ ឈ្មោះ [redacted] សុខហេង ចាប់ផ្ដើមធ្វើសកម្មភាពបង្កើតគណនីហ្វេសបុកដូចរបស់ខ្លួនមានឈ្មោះថា "[redacted] Sophim" បាន Post រូបភាពអាក្រាតកាយរបស់ ខ្លួនជាច្រើនរូបភាព និងបាន Add Story ជាវីដេអូ ហើយគាត់បានផ្ញើវីដេអូអាក្រាតកាយមកគំរាមខ្លួនថាគាត់នឹងលក់វីដេអូឱ្យទៅខាង You Tube ។ ឈ្មោះ [redacted] សុខហេង បានបង្កើតគណនីហ្វេសបុកឈ្មោះ "[redacted] Pov" បាន Post រូបភាពអាក្រាតកាយ ខ្លួនបានទាក់ទងទៅគាត់ដើម្បីសុំសម្រួលតែឈ្មោះ [redacted] សុខហេង មិនព្រម ហើយនៅតែបង្ហោះរូបភាពនឹងបានធ្វើសកម្មភាពលើគណនីដែលមានឈ្មោះដូចខាងលើ ដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់ខ្លួន និងគ្រួសារយ៉ាងធ្ងន់ធ្ងរ ទើបខ្លួនដាក់ពាក្យបណ្ដឹងទៅការិយាល័យសហប្រតិបត្តិការទប់ស្កាត់បទល្មើសព័ត៌មានវិទ្យា នៃនាយកដ្ឋានព័ត៌មានវិទ្យា ។

ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted] **ពិសត្តិ** បានឆ្លើយថា៖ កាលពីខែកុម្ភៈ ឆ្នាំ ២០២២ វេលាម៉ោងប្រហែល ១៩ និង ០៥ នាទី ខ្លួនអង្គុយលេងនៅផ្ទះជួលម្ដុំផ្សារឈូកមាស ខណ្ឌសែនសុខ រាជធានីភ្នំពេញ បានចូលមើលគណនីហ្វេសបុករបស់ខ្លួនឈ្មោះ "[redacted] PisaK" ឃើញគណនីហ្វេសបុកក្លែងឈ្មោះ [redacted] Sophim" បាន Post រូបភាពអាក្រាតកាយជាច្រើនសន្លឹកតាមបណ្ដាញទំនាក់ទំនងសង្គមហ្វេសបុករបស់ឈ្មោះ [redacted] សុភីម ភេទស្រី ជាមិត្តភក្តិធ្លាប់រៀនជាមួយគ្នានៅ



Scanned with CamScanner

វិទ្យាល័យព្រែកឆ្លៅ ស្រុកពារាំង ខេត្តព្រៃវែង ភ្លាមនោះខ្លួនបានឆាតតាមរយៈ Messenger សួរឈ្មោះ ព្រឿង សុភីម តើគណនីហ្វេសបុកឈ្មោះ “[redacted] Sophim“ មិនមែនជារបស់គាត់ទេ ហើយឈ្មោះ [redacted] សុភីម ក៏មិនបាន Post រូបអាក្រាតកាយខ្លួនឯងដែរ បន្ទាប់មកខ្លួនក៏បានប្រាប់ឈ្មោះ [redacted] សុភីម ទៅដាក់ពាក្យបណ្ដឹងនៅកន្លែងសមត្ថកិច្ច ។ បច្ចុប្បន្នគណនីហ្វេសបុកក្លែងឈ្មោះ “[redacted] Sophim“ នៅតែបន្ត Post រូបភាពអាក្រាតកាយឈ្មោះ[redacted] សុភីម តាមបណ្ដាញទំនាក់ទំនងសង្គមហ្វេសបុករហូត ។

**តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំ**

ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ និងអំណានចម្លើយជនរងគ្រោះ ,សាក្សី ឃើញថា: ជនជាប់ចោទឈ្មោះ [redacted] សុខហេង ហៅ សុខ ភេទប្រុស អាយុ ២៧ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើគំរាមកំហែងហែកកេរ្តិ៍មានស្ថានទម្ងន់ទោស ដោយសារការអនុវត្តជាក់ស្ដែងនូវការគំរាមកំហែង កាលពីថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២២ ពិតប្រាកដមែន ។ ដូច្នេះ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៤៦៦១ អ.យ.ធ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០២២ ដដែល សូមតុលាការពិនិត្យពិចារណា និងសម្រេចតាមច្បាប់ ។

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋាន**

នៅក្នុងរឿងនេះ កូនក្ដីខ្លួនបានឆ្លើយនៅចំពោះមុខអង្គសវនាការថា ខ្លួនពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់មែន ដោយសារតែកូនក្ដីខ្លួនមានការស្រលាញ់ជនរងគ្រោះខ្លាំងទើបបានប្រព្រឹត្តដូច្នេះ ហើយកូនក្ដីខ្លួនក៏បានដឹងកំហុស និងសុំធ្វើការកែប្រែខ្លួនឡើងវិញ ។ ហេតុនេះ ខ្លួនស្នើសុំឲ្យតុលាការជួយបន្ធូរបន្ថយទោសដល់កូនក្ដីខ្លួនផង ។

**ជនជាប់ចោទបាននិយាយសំដីចុងក្រោយ**

សុំឲ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ។

ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្ដាប់អំណានចម្លើយជនរងគ្រោះ

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១. តាមរបាយការណ៍សំយោគលេខ ០០៣/២២ របក.កង.៣៩ ចុះថ្ងៃទី២១ ខែ កក្កដា ឆ្នាំ ២០២២ របស់ការិយាល័យសហប្រតិបត្តិការទប់ស្កាត់បទល្មើសពត៌មានវិទ្យា និងភស្តុតាងទាំងអស់ដែលស្វែងរកដោយចៅក្រមស៊ើបសួរ ពុំមានភាពផ្ទុយគ្នាទេ ។ យោងតាមមាត្រា ១១០ និងមាត្រា ១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អាចឲ្យតុលាការជឿបានថា: កាលពីអំឡុងខែមីនា ឆ្នាំ ២០១៨ ឈ្មោះ [redacted] សុខហេង ហៅ សុខ ភេទប្រុស អាយុ ២៧ ឆ្នាំ និងជនរងគ្រោះឈ្មោះ[redacted]សុភីម ភេទស្រី អាយុ ២០ ឆ្នាំ ផ្ដើមមានទំនាក់ទំនងស្នេហាជាមួយគ្នា ឈានដល់ការលួងលោមឲ្យជនរងគ្រោះឈ្មោះ [redacted] សុភីម ផ្ញើរូបថតអាក្រាតកាយ និងឃ្លីបវីដេអូអាក្រាតកាយជនរងគ្រោះផ្ញើឲ្យជនជាប់ចោទ ។ រហូតមកដល់អំឡុងខែមេសា ឆ្នាំ ២០២០ ជនជាប់ចោទឈ្មោះ [redacted] សុខហេង ហៅ សុខ និងជនរងគ្រោះឈ្មោះ [redacted] សុភីម បានចាប់ផ្ដើមមានទំនាស់គ្នា ដោយហេតុថា ជនជាប់ចោទឈ្មោះ[redacted] សុខហេង តែងតែបបួលជនរងគ្រោះទៅផ្ទះសំណាក់ និងទាមទារឲ្យផ្ញើរូបថតអាក្រាត



Scanned with CamScanner

កាយជារឿយៗ ទើបជនរងគ្រោះបានផ្តាច់ទំនាក់ទំនងស្នេហាជាមួយឈ្មោះ [redacted] សុខហេង តែម្តង ។ ក្រោយពីជនរងគ្រោះផ្តាច់ទំនាក់ទំនងស្នេហាមក ឈ្មោះ [redacted] សុខហេង បានផ្ញើសារគំរាមជនរងគ្រោះតាមប្រព័ន្ធ SMS ឱ្យមកដេកផ្ទះសំណាក់ជាមួយខ្លួន បើមិនធ្វើតាមទេ នោះនឹងបង្ហោះរូបភាពអាក្រាតកាយ និងឃ្លីបវីដេអូអាក្រាតកាយរបស់ជនរងគ្រោះជាសាធារណៈ ។ នៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២២ ជនត្រូវចោទឈ្មោះ [redacted] សុខហេង ក៏បង្ហោះរូបភាពអាក្រាតកាយរបស់ជនរងគ្រោះ តាមគណនីហ្វេសបុកឈ្មោះ [redacted] Sophim" និងនៅថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០២២ បានបង្ហោះរូបភាពអាក្រាតកាយ ព្រមទាំងវីដេអូអាក្រាតកាយរបស់ជនរងគ្រោះ តាមរយៈគណនីហ្វេសបុកឈ្មោះ [redacted] Pov" ដោយភ្ជាប់ខ្លឹមសារសសេរថា "នឹកអូនណាស់មើលលេងសិនទៅសម្រាប់អ្នកឡាស់តិចទៀតឃើញរឿងហើយលក់ឱ្យគេ"។ រហូតដល់ថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០២២ ជនរងគ្រោះឈ្មោះ [redacted] សុភីម បានមកដាក់ពាក្យបណ្តឹងនៅនាយកដ្ឋានពត៌មានវិទ្យា នៃក្រសួងមហាផ្ទៃ ឈានដល់ការឃាត់ខ្លួនជនត្រូវចោទឈ្មោះ [redacted] សុខហេង ហៅ សុខ នៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០២២ នាំយកមកសាកសួរតែម្តង ។

២.តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សុខហេង បានឆ្លើយសារភាពនាពេលសវនាការថា៖ កាលពីថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២២ និងថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០២២ ខ្លួនពិតជាបានធ្វើសកម្មភាពប្រព្រឹត្តអំពើគំរាមគំហែងហែកកេរ្តិ៍មានស្ថានទម្ងន់ទោសដោយសារការអនុវត្តជាក់ស្តែងនូវការគំរាមគំហែង ដូចការចោទប្រកាន់របស់តំណាងអយ្យការមែន ដែលចម្លើយសារភាពរបស់ជនជាប់ចោទ ស្របនឹងចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] សុភីម និងចម្លើយសាក្សីឈ្មោះ [redacted] ពិសក្តិ ដែលបានឆ្លើយនៅចៅក្រមស៊ើបសួរ និងរបាយការណ៍របស់ការិយាល័យសហប្រតិបត្តិការទប់ស្កាត់បទល្មើសពត៌មានវិទ្យា ដែរ ។

ភស្តុតាងទាំងអស់នេះតុលាការអាចលើកយកមកពិចារណាបានតាមមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣. ជនជាប់ចោទឈ្មោះ [redacted] សុខហេង ហៅ សុខ ជានីតិជនមានស្មារតីគ្រប់គ្រាន់ នៅពេលប្រព្រឹត្តបទល្មើសពុំមានជំងឺវិបល្លាសស្មារតីទេ ។ ជាសមត្ថជនមានសមត្ថភាពពេញលេញក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនតាមផ្លូវច្បាប់ ស្របតាមមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ ។

៤. អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈសន្តិសុខសង្គម ដែលក្រមព្រហ្មទណ្ឌត្រង់មាត្រា ២ និង ៣ បានហាមឃាត់ដាច់ខាត និងត្រូវតែផ្តន្ទាទោស ។ ម្យ៉ាងទៀត អំពើនេះមានធាតុផ្សំគ្រប់គ្រាន់ពីបទៈ គំរាមគំហែងហែកកេរ្តិ៍ដ៏ចមានស្ថានទម្ងន់ទោសដោយសារការអនុវត្តជាក់ស្តែងនូវការគំរាមគំហែង ។

៥. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភីម ប្តឹងទាមទារសំណងការខូចខាត និងជម្ងឺចិត្តចំនួន ២០.០០០ (ពីរម៉ឺនដុល្លារអាមេរិក) ។ គប្បីតុលាការពិចារណា សម្រេចអំពីសំណងនេះ និងលទ្ធភាពជនជាប់ចោទ ។

៦. វត្ថុចាប់យកមាន៖

- ទូរស័ព្ទដៃម៉ាក ViVo ពណ៌ខៀវ ចំនួន ០១ គ្រឿង (មិនដំណើរការ) ។
- ទូរស័ព្ទដៃម៉ាក NOKIA ពណ៌ផ្ទៃមេឃ ចំនួន ០១ គ្រឿង (មិនដំណើរការ) ។
- ប្រាក់រៀលចំនួន ៧,០០០ (ប្រាំពីរពាន់) រៀល ។
- នាឡិការដៃម៉ាក CHAXIGOពណ៌ខ្មៅចំនួន ០១គ្រឿង (មិនដំណើរការ) ។
- កាបូបដៃ ពណ៌ខ្មៅ ចំនួន ០១ (មួយ) ។

គប្បីតុលាការពិនិត្យ និងសម្រេច ។



Scanned with CamScanner

៧. មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុខហេង ហៅ សុខ ភេទប្រុស អាយុ ២៧ ឆ្នាំ ពីបទ គំរាមគំហែងហែកកេរ្តិ៍មានស្ថានទម្ងន់ទោសដោយសារការអនុវត្តជាក់ស្តែងនូវការគំរាមគំហែង ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២២ និងថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៧២ និងមាត្រា ៣៧៤ នៃក្រមព្រហ្មទណ្ឌ ។

**ហេតុដូច្នេះសម្រេច**

១. ផ្តន្ទាទោសលើឈ្មោះ [redacted] **សុខហេង** ហៅ សុខ ភេទប្រុស អាយុ ២៧ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ (ប្រាំឆ្នាំ) ។

ពីបទ គំរាមគំហែងហែកកេរ្តិ៍មានស្ថានទម្ងន់ទោសដោយសារការអនុវត្តជាក់ស្តែងនូវការគំរាមគំហែង ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០២២ និងថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៧២ និងមាត្រា ៣៧៤ នៃក្រមព្រហ្មទណ្ឌ ។

២. បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] **សុខហេង** ហៅ **សុខ** សងការខូចខាត និងជម្ងឺចិត្តចំនួន ១០.០០០.០០០ (ដប់លានរៀល) ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុភីម** ។ ច្រានចោលការទាមទារលើសពីនេះ ។

៣. វត្ថុចាប់យកមាន៖

- ទូរស័ព្ទដៃម៉ាក ViVo ពណ៌ខៀវ ចំនួន ០១ គ្រឿង (មិនដំណើរការ) និងទូរស័ព្ទដៃម៉ាក NOKIA ពណ៌ផ្ទៃមេឃ ចំនួន ០១ គ្រឿង (មិនដំណើរការ) **រឹបអូស** ។

- ប្រាក់រៀលចំនួន ៧,០០០ (ប្រាំពីរពាន់) រៀល ,នាឡិកាដៃម៉ាក CHAXIGOពណ៌ខ្មៅចំនួន ០១គ្រឿង (មិនដំណើរការ) និងកាបូបដៃ ពណ៌ខ្មៅ ចំនួន ០១ (មួយ) ប្រគល់ឱ្យម្ចាស់ដើមវិញ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០២៣ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០២៣ ។

បើកសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ០១កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០២៣

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner